ពត៌មានស្តីអំពី Commonwealth Care ដែលជាកម្មវិធី
មួយរបស់ម៉ាសហិលឬមេឌីខេត
WUML
10/1/06

Commonwealth Care គឺជាកម្មវិធីជំនួយចេញថ្លៃពេទ្យមួយប្រភេទ ដែលផ្តល់ឡើងដោយ Commonwealth Health Insurance Connector ឬ Connector។ កម្មវិធីនេះ អាចជួយចេញថ្លៃពេទ្យ សំរាប់ពលរដ្ឋទាំងអស់ដែលរស់នៅក្នុងម៉ាសាឈូសេត្សហើយ ដែលអាចមានសិទ្ធនឹងទទួលជំនួយនេះបាន ដោយមានការទាក់ទងជាមួយទៅនឹងគំរោងធានារ៉ាប់រងសុខភាពដទៃទៀត ដែលរដ្ឋយល់ព្រមធ្វើសហាការជាមួយ។

កម្មវិធី Connector អាចជួយសមាជិក Commonwealth Care ឲ្យចូលរួមក្នុងគំរោងធារ៉ាប់រងសុខភាព ណាមួយ ហើយអាចជួយរកគ្រូពេទ្យប្រចាំកាយ ប្រសិនបើសមាជិកនោះត្រូវរក។ គំរោងធានារ៉ាប់រងសុខភាពទាំងនោះ នឹងធ្វើការយ៉ាងជិតស្និតជាមួយគ្រូពេទ្យ, មន្ទីរពេទ្យ, និងមណ្ឌលសុខភាពនានា ដើម្បីផ្តល់កិច្ចព្យាបាលសុខភាព ដែលលោកអ្នកត្រូវការចាំបាច់។ ក្រុមហ៊ុនដែលចូលរួម ក្នុងកម្មវិធី Connector មានដូចជា ៖ Fallon Community Health Plan, Network Health Plan, Neighborhood Health Plan, និង Boston Medical Center HealthNet Plan។

អ្នកដែលអាចមានសិទ្ធនឹងទទួលជំនួយពីកម្មវិធី Connector បានគឺ អ្នកដែល៖ ពុំមានក្រុមហ៊ុនធានារ៉ាប់រងសុខភាព, ជនជាតិអាមេរិកាំង/អ្នកចូលសញ្ជាតិអាមេរិកាំង/អ្នកមានសិទ្ធរស់នៅ ក្នុងសហរដ្ឋដោយស្របច្បាប់, អ្នកដែលមានប្រាក់ចំណូលក្នុងគ្រួសារតិចជាង 300% នៃក៏រិតដែលរដ្ឋាភិបាលសហរដ្ឋបានកំណត់, អ្នកដែលមានអាយុពី 19 ឆ្នាំឡើងទៅ, និងអ្នកដែលពុំមានសិទ្ធទទួលជំនួយចេញថ្លៃពេទ្យពីក្រុមហ៊ុនធានារ៉ាប់រងសុខភាពណាមួយ ឬពីកម្មវិធីម៉ាស់ហិលនិងមេឌីយា។

ចាប់ពីថ្ងៃទី 1 ខែ តុលាឆ្នាំ 2006 នេះតទៅ អ្នកដែលដាក់ពាក្យសុំជំនួយម៉ាសហីលទាំងអស់ នឹងត្រូវពិនិត្យមើលថា តើអាចត្រូវបានជំនួយទាំងប៉ុន្មានដូចតទៅនេះ ឬពុំបាន។ ជំនួយទាំងនេះ គឺ

មាន ម៉ាស់ហិល (MassHealth), កុំម៉នវិលឃា (Commonwealth Care), ជំនួយព្យាបាលដោយពុំបាច់ចេញថ្លៃ (Uncompensated Care ឬ Free Care), ហិលធីស្តាត (Healthy Start) និងគំរោងជំនួយចេញថ្លៃព្យាបាលសំរាប់ក្មេង ហៅថា Children's Medical Security Plan ។

អ្នកដែលកំពុងទទួលជំនួយព្យាបាលដោយពុំបាច់ចេញថ្លៃ (Uncompensated Care ឬ Free Care) ដែលមានប្រាក់ចំណូលក្នុងគ្រួសារតិចជាង 100% នឹងត្រូវបានទទួលលិខិតសំរាប់ឲ្យចូលរួមក្នុងកម្មវិធីកុំម៉នវិលឃា (Commonwealth Care)។ អ្នកទាំងនោះពុំបាច់ដាក់ពាក្យសុំសារជាថ្មី ម្តងទៀតឡើយ។ ប៉ុន្តែ គាត់ត្រូវដាក់ពាក្យសុំចូលរួមក្នុងគំរោងធានារ៉ាប់រងសុខភាពណាមួយ ដែលខ្ញុំបាទបានរៀបរាប់ពីមុនមក គឺ Fallon Community Health Plan, Network Health Plan, Neighborhood Health Plan, និង Boston Medical Center HealthNet Plan ។ សូមបញ្ជាក់ថា លោកអ្នកត្រូវដាក់ពាក្យសុំចូលរួមក្នុងគំរោងទាំងនោះ គឺពាក្យអង់គ្លេសហៅថា enroll គឺ ពុំមែនបានន័យថា ទិញ ដូចជាទិញអ៊ិនស្វ៊ូរិន (Insurance) រថយន្ត ឬទិញអ៊ិនស្វ៊ូរិន insurance ផ្ទះនោះឡើយ។ ឯការដាក់ពាក្យសុំ ឬ enroll នេះ គឺបានន័យម្យ៉ាងទៀតថា រដ្ឋត្រូវពិនិត្យមើលទៅតាម ប្រាក់ចំណូលក្នុងគ្រួសារ ដើម្បីអាចចូលរួមក្នុងកម្មវិធីនេះបាន។

ដូច្នេះ ខ្ញុំបាទសុំអំពាវនាវដល់ អស់លោក-លោកស្រី ដែលអញ្ជើញទៅព្យាបាលសុខភាព នៅមណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល ដែលកំពុងទទួលជំនួយព្យាបាលដោយពុំបាច់ចេញថ្លៃ (Uncompensated Care ឬ Free Care) ដែលមានប្រាក់ចំណូលក្នុងគ្រួសារតិចជាង 100% ហើយបានទទួលលិខិតសំរាប់ ឲ្យចូលរួមក្នុងកម្មវិធីកុំម៉នវិលឃា (Commonwealth Care) នេះ សូមអញ្ជើញទៅជួបជាមួយបុគ្គលិកជួយដាក់ពាក្យសុំជំនួយចេញថ្លៃព្យាបាល ដើម្បីឲ្យគេជួយដាក់ពាក្យសុំចូលរួមក្នុង គំរោងធានារ៉ាប់រង សុខភាពណាមួយឲ្យ ទៅតាមបំណងរបស់លោកអ្នក។

សូមបញ្ជាក់ម្តងទៀតថា អស់លោក-លោកស្រីដែលកំពុងទទួល ជំនួយព្យាបាលដោយពុំបាច់ចេញថ្លៃ (Uncompensated Care ឬ Free Care) សូមអញ្ជើញទូរស័ព្ទទៅ មណ្ឌលសុខភាពដែលលោកអ្នកអញ្ជើញទៅព្យាបាល ឬដែលលោកអ្នកដាក់ពាក្យសុំជំនួយនេះពីមុន។ ចំពោះអស់លោក-លោកស្រីដែលទទួលជំនួយព្យាបាលដោយពុំបាច់ចេញថ្លៃ (Uncompensated Care ឬ Free Care) នៅមណ្ឌលមេត្តាសុខភាព សូមទូរស័ព្ទទៅ លេខ

(978) 441-1700។ សូមបញ្ជាក់ថា លេខទូរស័ព្ទនេះគឺសំរាប់តែអស់លោក-លោកស្រីដែលទទួលជំនួយព្យាបាលដោយពុំបាច់ចេញថ្លៃ (Uncompensated Care ឬ Free Care) នៅមណ្ឌលមេត្តាសុខភាព តែប៉ុណ្ណោះ។

ម្យ៉ាងទៀត ឆ្លៀតឱកាសនេះ ខ្ញុំបាទក៏ សូមជំរាបបញ្ជាក់ផងដែរថា មណ្ឌលមេត្តាសុខភាពនៃមណ្ឌលសុខភាពសហគមន៍ក្រុងឡូវែល អាចមានលទ្ធភាព តែជួយបំពេញលិខិតដាក់ពាក្យសុំជំនួយ ចេញថ្លៃព្យាបាលសុខភាព បានតែសំរាប់អស់លោក-លោកស្រី ដែលអញ្ជើញទៅពិនិត្យព្យាបាលសុខភាពនៅមណ្ឌលនេះតែប៉ុណ្ណោះ ហើយឯការអនុមតិថា តើអស់លោក-លោកស្រីអាចមានសិទ្ធនឹងទទួលជំនួយនេះបាន ឬពុំបាននោះ គឺអាស្រ័យទៅលើ ការអនុមតិនៃរដ្ឋាភិបាលរដ្ឋម៉ាសាឈូសេត្ស និងអាស្រ័យទៅលើពត៌មាន ដែលអស់លោក-លោកស្រីបានប្រាប់ឲ្យបំពេញ និងឯកសារផ្សេងៗដែលអស់លោក-លោកស្រី ផ្ញើភ្ជាប់ជាមួយ ក្នុងលិខិតដាក់ពាក្យនោះ។ មណ្ឌលមេត្តាសុខភាព ពុំមែនជាអ្នកអនុមតិ ទៅលើការសុំទទួលជំនួយ ចេញថ្លៃព្យាបាលទាំងនោះឡើយ។